គោលជំនឿ៖ ផ្នែកទីបី

សាឡូមភ្នំពេញ

# ព្រះវិញ្ញាណ បរិសុទ្ធ

# ព្រះវិញ្ញាណបរិសុទ្ធ

*យើងខ្ញុំជឿថា ព្រះវិញ្ញាណបរិសុទ្ធ ជាអង្គដែលបើកសម្ដែង អំពីព្រះគ្រីស្ទ ហើយឲ្យមនុស្សលោកដឹងច្បាស់ថាខ្លួនមាន បាប។ ទ្រង់ប្រោសឲ្យមនុស្សដែលស្លាប់ខាងឯវិញ្ញាណមាន ជីវិតថ្មី ហើយគង់នៅក្នុងអ្នកជឿទាំងអស់។*

ទ្រង់ក៏ញែកពួកគេជាបរិសុទ្ធ ព្រមទាំងផ្តល់កំលាំងឲ្យពួកគេ
ចេះបម្រើក្នុងពួកជំនុំទៀតផង។ ព្រះវិញ្ញាណបរិសុទ្ធជួយឲ្យ
អ្នកជឿយល់បទគម្ពីរ ហើយដៅចំណាំអស់អ្នកជឿ ព្រមទាំង
ធ្វើជាសាក្សីនៅក្នុងដួងចិត្តរបស់ពួកគេថា ពួកគេគឺជាកូន
របស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។

# យើងខ្ញុំជឿថា ព្រះវិញ្ញាណបរិសុទ្ធ ជាអង្គដែលបើកសម្ដែងអំពីព្រះគ្រីស្ទ

# ១) យ៉ូហាន ១៥:២៦ ទំព័រ ១៣៩២

ប៉ុន្តែកាលណាព្រះដ៏ជាជំនួយទ្រង់យាងមក ដែលខ្ញុំនឹងចាត់មកពីព្រះវរបិតា គឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលចេញពីព្រះវរបិតាមក ព្រះអង្គនោះ ទ្រង់នឹងធ្វើបន្ទាល់ពីខ្ញុំ

# ២ ) យ៉ូហាន ១៦:១៣, ១៤ ទំព័រ ១៣៩២

កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្ដីពិតបានមកដល់....ទ្រង់នឹងដំកើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្ដីដែលជំរូវពីខ្ញុំមកប្រាប់ដល់អ្នករាល់គ្នា

# ហើយឲ្យមនុស្សលោកដឹងច្បាស់ថាខ្លួនមានបាប។

# ៣) យ៉ូហាន ១៦:៨ ទំព័រ ១៣៩២

២៧, ១៣

កាលណាទ្រង់បានយាងមកហើយ នោះទ្រង់នឹងសំដែង ឲ្យមនុស្សលោកដឹងច្បាស់ ពីអំពើបាប ពីសេចក្ដីសុចរិត ហើយពីសេចក្ដីជំនុំជំរះ

# ទ្រង់ប្រោសឲ្យមនុស្សដែល ស្លាប់ខាងវិញ្ញាណមានជីវិតថ្មី

## ៤) ទីតុស ៣:៥ ទំព័រ ១៥៤៩

នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្ដីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្ដីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ

# ៥) យ៉ូហាន ៦:៦៣ ទំព័រ ១៣៧៥

គឺជា[ព្រះ]វិញ្ញាណដែលឲ្យមានជីវិត រូបសាច់គ្មានប្រយោជន៍អ្វីទេ ឯពាក្យដែលខ្ញុំនិយាយនឹងអ្នករាល់គ្នា នោះត្រូវខាងវិញ្ញាណនឹងជីវិតវិញ

មានតែព្រះវិញ្ញាណទេដែលផ្ដល់ជីវិត និស្ស័យលោកីយ៍គ្មានប្រយោជន៍អ្វីឡើយ។ រីឯពាក្យទាំងប៉ុន្មានដែលខ្ញុំបាននិយាយប្រាប់អ្នករាល់គ្នា សុទ្ធតែចេញមកពីព្រះវិញ្ញាណដែលផ្ដល់ជីវិត។ *(ព្រះគម្ពីរខ្មែរបច្ចុប្បន្ន ២០០៥)*

# ហើយគង់នៅក្នុងអ្នកជឿទាំងអស់។

# ៦) ១កូរិនថូស ៣:១៦ ទំព័រ ១៨៧៥

តើអ្នករាល់គ្នាមិនដឹងទេឬអី ថាខ្លួនអ្នករាល់គ្នាជាព្រះវិហារនៃព្រះ ហើយថា ព្រះវិញ្ញាណនៃព្រះ ទ្រង់សណ្ឋិតក្នុងអ្នករាល់គ្នា

សណ្ឋិត ឬ គង់នៅ?    oἰκέω = រស់នៅ, ស្នាក់នៅ, នៅជាមួយ

# ព្រះវិញ្ញាណបរិសុទ្ធ

*ទ្រង់ក៏ញែកពួកគេជាបរិសុទ្ធ ព្រមទាំងផ្ដល់កំលាំងឲ្យពួកគេចេះបម្រើក្នុងពួកជំនុំទៀតផង។ ព្រះវិញ្ញាណបរិសុទ្ធជួយឲ្យអ្នកជឿយល់បទគម្ពីរ ហើយដៅចំណាំអស់អ្នកជឿ ព្រមទាំងធ្វើជាសាក្សីនៅក្នុងដួងចិត្តរបស់ពួកគេថា ពួកគេគឺជាកូនរបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។*

# ទ្រង់ក៏ញែកពួកគេជាបរិសុទ្ធ

# ៧) ២ថែស្សាឡូនីច ២:១៣ ទំព័រ ១៥៣៦

ឱបងប្អូនដ៏ជាស្ងួនភ្ងានៃព្រះអម្ចាស់អើយ យើងខ្ញុំត្រូវតែអរព្រះគុណដល់ព្រះអង្គជានិច្ច ពីដំណើរអ្នករាល់គ្នា ពីព្រោះព្រះទ្រង់បានរើសអ្នករាល់គ្នា តាំងពីដើមដំបូងមក ដើម្បីឲ្យបានសង្គ្រោះ ដោយព្រះវិញ្ញាណទ្រង់ញែកចេញជាបរិសុទ្ធ ហើយដោយមានចិត្តជឿ តាមសេចក្ដីពិតផង

# ៨) រ៉ូម ៨:១៣ ទំព័រ ១៤៥៦

ដ្បិតបើសិនជាអ្នករាល់គ្នារស់តាមសាច់ឈាម នោះនឹងត្រូវស្លាប់ទៅ តែបើសំឡាប់អំពើរបស់រូបសាច់ចេញ ដោយសារព្រះវិញ្ញាណ នោះអ្នករាល់គ្នានឹងបានរស់វិញ

# ព្រមទាំងផ្ដល់កំលាំងឲ្យពួកគេ ចេះបម្រើក្នុងពួកជំនុំទៀតផង។

# ៩) កិច្ចការ ១:៨ ទំព័រ ១៨០២

ប៉ុន្តែ កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនឹងធ្វើជាទីបន្ទាល់ពីខ្ញុំ នៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា នឹងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង

# ១០) ១កូរិនថូស ១២:៤, ៧, ១១ ទំព័រ ១៤៨៤

[៤]រីឯអំណោយទាន នោះមានផ្សេងៗពីគ្នា តែគឺជាព្រះវិញ្ញាណ
ដដែលទេ...[៧]ហើយទ្រង់ប្រទានឲ្យព្រះវិញ្ញាណសំដែងមកក្នុង
គ្រប់គ្នា ដើម្បីឲ្យបានកើតផល [ដើម្បីជាប្រយោជន៍រួម]...[១១]តែ
គឺជាព្រះវិញ្ញាណតែមួយដដែលនោះឯង ដែលធ្វើគ្រប់ការទាំង
នោះ ទាំងចែកដល់គ្រប់គ្នាដោយមុខៗផង តាមដែលទ្រង់
សព្វព្រះហឫទ័យ ។

# ព្រះវិញ្ញាណបរិសុទ្ធជួយឲ្យអ្នកជឿយល់បទគម្ពីរ

# ១១) យ៉ូហាន ១៦:១៣ ទំព័រ ១៣៩២

កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្ដីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្ដីពិត ដ្បិតទ្រង់នឹងមានបន្ទូល មិនមែនដោយអាងព្រះអង្គទ្រង់ទេ គឺនឹងមានបន្ទូល ចំពោះតែសេចក្ដីណាដែលទ្រង់ឮ ហើយនឹងសំដែង ឲ្យអ្នករាល់គ្នាដឹងការដែលត្រូវមក

ហើយដៅចំណាំអស់អ្នកជឿ ព្រមទាំងធ្វើជាសាក្សីនៅក្នុងដួងចិត្តរបស់ពួកគេថា ពួកគេគឺជាកូនរបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដ។

# ១២ ) អេភេសូរ ១:១៣ ទំព័រ ១៥១៣

...ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំ ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា

# ១៣ ) រ៉ូម ៨:១៦ ទំព័រ ១៤៦០

ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើង
ជាកូនរបស់ព្រះ


ព្រះវរបិតា
ព្រះរាជបុត្រា
ព្រះវិញ្ញាណបរិសុទ្ធ
ព្រះ
ជា
ជា
ជា
មិនមែន
មិនមែន
មិនមែន